ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០៧១.....អ. ស. ហ.ប្រក.

ប្រកាស
ស្តីពី
ការកែសម្រួលប្រការ១២ ប្រការ២៥ ប្រការ៣១ ប្រការ៣៤ ប្រការ៤០ ប្រការ៤១ ប្រការ៤២ ប្រការ៤៣ និងប្រការ៤៥ នៃប្រកាសលេខ ០៤៧ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញប្រកាសលេខ ០០៨ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ
- បានឃើញប្រកាសលេខ ០៤៧ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

សម្រេច

ប្រការមួយ.-

ប្រការ១២ ប្រការ២៥ ប្រការ៣១ ប្រការ៣៤ ប្រការ៤០ ប្រការ៤១ ប្រការ៤២ ប្រការ៤៣ និងប្រការ៤៥ នៃប្រកាសលេខ ០៤៧ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ត្រូវបានកែសម្រួលដូចតទៅ៖

ប្រការ១២.-ថ្មី

ន.អ.ប. ឬមន្ទីរមានសិទ្ធិសម្រេចផ្តល់ ឬបដិសេធចំពោះការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មក្នុងរយៈពេល ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ក្នុងករណីបដិសេធចំពោះការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម **ន.អ.ប**. ឬមន្ទីរត្រូវជូនដំណឹងទៅបុគ្គលស្នើសុំដោយបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។

ប្រការ២៥.-ថ្មី

ន.អ.ប. ឬមន្ទីរត្រូវចេញលិខិតអនុញ្ញាត ឬបដិសេធសំណើសុំដកប្រាក់តម្កល់ធានាអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**. និងបន្ទាប់ពីមានការចុះវាយតម្លៃជាក់ស្តែងដល់ទីកន្លែងពី **ន.អ.ប**. ឬមន្ទីរ។

ប្រការ៣១.-ថ្មី

រាល់ការកែប្រែ ឬផ្លាស់ប្តូរអាសយដ្ឋានក្រុមហ៊ុន នាមករណ៍ក្រុមហ៊ុន ឈ្មោះគម្រោង ភាគហ៊ុនិក សមាសភាពក្រុមប្រឹក្សាភិបាល អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ឬអ្នកឈរឈ្មោះលើលិខិតអនុញ្ញាតអាជីវកម្ម កម្មវត្ថុអាជីវកម្ម ប្រភេទលំនៅឋាន ឬអគារសហកម្មសិទ្ធិ ទំហំដីឡូត៍ បុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវស្នើសុំការឯកភាពជាគោលការណ៍ជាមុនពី **ន.អ.ប**. ឬមន្ទីរ។

ន.អ.ប. ឬមន្ទីរត្រូវជូនដំណឹងអំពីការអនុញ្ញាត ឬការបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ប្រការ៣៤.-ថ្មី

ន.អ.ប. ឬមន្ទីរមានសិទ្ធិសម្រេចបន្តសុពលភាព ឬបដិសេធចំពោះការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ក្នុងករណីបដិសេធចំពោះការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម **ន.អ.ប**. ឬមន្ទីរត្រូវជូនដំណឹងទៅបុគ្គលស្នើសុំដោយបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។

ប្រការ៤០.-ថ្មី

ន.អ.ប. ឬមន្ទីរត្រូវចេញលិខិតបញ្ជាក់ការយល់ព្រម ឬបដិសេធចំពោះការស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឬបញ្ចប់គម្រោង របស់បុគ្គលអភិវឌ្ឍអចលនវត្ថុបន្ទាប់ពីការត្រួតពិនិត្យសំណុំឯកសារ និង/ឬការចុះវាយតម្លៃជាក់ស្តែងពីមន្ត្រីជំនាញមានសមត្ថកិច្ចរបស់ **ន.អ.ប**. ឬមន្ទីរក្នុងរយៈពេល ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលត្រូវបានព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មត្រូវបញ្ឈប់សកម្មភាពអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ចាប់ពីកាលបរិច្ឆេទចេញលិខិតជាលាយលក្ខណ៍អក្សរដោយ **ន.អ.ប**. ឬមន្ទីរ។

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលត្រូវបានព្យួរសកម្មភាពអាជីវកម្ម អាចចាប់ផ្តើមដំណើរការឡើងវិញលុះត្រាតែបុគ្គលអភិវឌ្ឍនោះបានបំពេញកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន និងដាក់ពាក្យស្នើសុំប្រកបអាជីវកម្មឡើងវិញដោយមានលិខិតឯកភាពជាលាយលក្ខណ៍អក្សរពី **ន.អ.ប**. ឬមន្ទីរ។

ប្រការ៤១.-ថ្មី

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលស្នើសុំអាជ្ញាបណ្ណពី **ន.អ.ប**. ឬលិខិតអនុញ្ញាតអាជីវកម្មពីមន្ទីរ ត្រូវបង់កម្រៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម កម្រៃសេវារដ្ឋបាល ដូចមានកំណត់ទៅតាមប្រភេទ និងចំនួនដូចខាងក្រោម៖

តម្លៃគិតជារៀល/ឯកតា

ប្រភេទ	ចំនួន	កម្រៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតអាជីវកម្ម	កម្រៃសេវារដ្ឋបាល
សំណង់ផ្ទះល្វែង	១ ល្វែង	៩០.០០០	៣៦.០០០
សំណង់ភូមិគ្រឹះ	១ ភូមិគ្រឹះស្ពោះ	១០៨.០០០	៥៤.០០០
	១ ភូមិគ្រឹះទោល	១៨០.០០០	៩០.០០០

សំណង់អគារសហកម្មសិទ្ធិ	ចាប់ពី ១ ដល់ ២ បន្ទប់គេង	៩0.000	៥៤.000
	៣ បន្ទប់គេងឡើងទៅ	១៨0.000	៩0.000
	តូបផ្សារ ឬអគារការិយាល័យ (គិតជាម៉ែត្រការ៉ែ)	១.៣៥0	៤៥0
ដីឡូត៍	ក្រោម ២00 ម៉ែត្រការ៉ែ/ឡូត៍	៣៦.000	១៨.000
	ចាប់ពី ២00 ដល់ ៥00 ម៉ែត្រការ៉ែ/ឡូត៍	៧២.000	៣៦.000
	លើសពី ៥00 ដល់ ១.000 ម៉ែត្រការ៉ែ/ឡូត៍	១0៨.000	៥៤.000
	លើសពី ១.000 ម៉ែត្រការ៉ែ/ឡូត៍ឡើងទៅ	១៨0.000	៩0.000

ប្រការ៤២.-ថ្មី

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ត្រូវបង់កម្រៃសេវារដ្ឋបាលដូចមានចែងក្នុងប្រការ៤១ ថ្មី នៃប្រកាសនេះ។

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតជាគោលការណ៍ ត្រូវបង់កម្រៃសេវារដ្ឋបាលចំនួន ៩00.000 (ប្រាំបួនរយពាន់) រៀល ក្នុង ១ (មួយ) លើក។

ប្រការ៤៣.-ថ្មី

រាល់ការកែប្រែ ឬផ្លាស់ប្តូរអាសយដ្ឋានក្រុមហ៊ុន នាមករណ៍ក្រុមហ៊ុន ឈ្មោះគម្រោង ភាគហ៊ុនិក សមាសភាពក្រុមប្រឹក្សាភិបាល អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ឬអ្នកឈរឈ្មោះលើលិខិតអនុញ្ញាតអាជីវកម្ម កម្មវត្ថុអាជីវកម្ម ប្រភេទលំនៅឋាន ឬអគារសហកម្មសិទ្ធិ ទំហំដីឡូត៍ បុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវបង់កម្រៃសេវារដ្ឋបាលចំនួន ១.៨00.000 (មួយលានប្រាំបីរយពាន់) រៀល ក្នុង ១ (មួយ) លើក សម្រាប់បុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ និងចំនួន ៤៥0.000 (បួនរយហាសិបពាន់) រៀល ក្នុង ១ (មួយ) លើក សម្រាប់បុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានលិខិតអនុញ្ញាតអាជីវកម្ម។

ប្រការ៤៥.-ថ្មី

បុគ្គលស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មពី **ឧ.អ.ប**. ឬមន្ទីរ ត្រូវបង់ភាគទានសម្រាប់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យអចលនវត្ថុនិងវិស័យបញ្ចាំត្រូវបានកំណត់ទៅតាមប្រភេទ និងចំនួនដូចខាងក្រោម៖

តម្លៃគិតជារៀល/ឯកតា

ប្រភេទ	ចំនួន	ភាគទាន
សំណង់ផ្ទះល្វែង	១ ល្វែង	២២.៥00
សំណង់ភូមិគ្រឹះ	១ ភូមិគ្រឹះស្ពោះ	៣៦.000
	១ ភូមិគ្រឹះទោល	៥៤.000

សំណង់អគារសហកម្មសិទ្ធិ	ចាប់ពី ១ ដល់ ២ បន្ទប់គេង	៣៦.000
	៣ បន្ទប់គេងឡើងទៅ	៥៤.000
	តូបផ្សារ ឬអគារការិយាល័យ (គិតជាម៉ែត្រការ៉េ)	៣៦0
ដីឡូត៍	ក្រោម ២00 ម៉ែត្រការ៉េ/ឡូត៍	៩.000
	ចាប់ពី ២00 ដល់ ៥00 ម៉ែត្រការ៉េ/ឡូត៍	១៨.000
	លើសពី ៥00 ដល់ ១.000 ម៉ែត្រការ៉េ/ឡូត៍	៣៦.000
	លើសពី ១.000 ម៉ែត្រការ៉េ/ឡូត៍ឡើងទៅ	៥៤.000

កម្រៃភាគទានដូចមានកំណត់ក្នុងតារាងនៃប្រការនេះត្រូវបង់ចូលគណនីរបស់ **ន.អ.ប**.។

ប្រការពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការបី.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តកររាជីវកម្មអចលនវត្ថុ និងបញ្ចាំ អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៤ កើត ខែ ភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧0
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២0២៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួលៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-ឧទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
"ដើម្បីជូនជ្រាប"
-ដូចប្រការបី "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ